អាយ៉ងពីក្រុមមួយរួចផ្លាស់ទៅក្រុមមួយទៀត បណ្ដាក់គ្នាសម្លាប់បំផុតពូជខ្មែរជាដំណាក់ៗបានយ៉ាងស្ទាត់ជំនួសវា ។ យួនហាណូយធ្វើព្រងើយសំរាកសម្ងំរង់ចាំឱកាសល្អទើបវាឈានមួយជំហានៗ យ៉ាងអាថ៌កំបាំងហាក់ក្រោកឡើង កញ្ឆក់យកជោគជ័យតែម្ដង ។ ដូចជាថ្ងៃទី១៧មេសា១៩៧៥ជាដើម គឺយួនហាណូយជាវៀតកុងទេតើ ជាអ្នកទទួលជ័យជំនះដ៏មហាអស្ចារ្យមហាលោតផ្លោះនោះ ។ ប៉ុន្តែវាប្រើឈ្មោះអង្គការអនាមិកជាមេបញ្ជាការយ៉ាងជិតអន្ធកាជាស្ថាពរ ។

អង្គការគិតតែពីសម្លាប់បំផុតពូជខ្មែរ ហើយនៅពេលជាមួយគ្នានេះដែរ អង្គការបែរជាបញ្ចូលវៀតកុងមកកាន់ប្រទេសខ្មែរទាំងក្រុមៗ ។ ក្រុមខ្លះដើរប្រមូលអណិកជនយួន ដឹកនាំយកទៅទុកនៅស្រុកយួន ទុកឆ្អែប្រឌិតបន្លំធ្វើជាខ្មែរទៅអនាគត ក្រុមផ្សេងទៀតដើរប្រមូលទ្រព្យសម្បត្តិ ក្នុងមួយនគរខ្មែរ ប្លន់ដឹកនាំចេញដោយសេរី ។ ទីបំផុតអង្គការបំផ្លាញប្រទេសខ្មែរឲ្យរលាយទៅជាផេះ ។ វាបង្កើតឃាតករជាច្រើនក្រុម ដាច់ៗដោយឡែកពីគ្នា ។ វាមានបង្កើតក្រុមឃាតករអាថ៌កំបាំង រួចទើបវាបញ្ចេញជាលំដាប់លំដោយ កំណត់ថ្ងៃខែឆ្នាំយ៉ាងត្រឹមត្រូវ ។

★ ដូចជាឃាតករក្រុមទី១ ៖ ត្រូវសម្លាប់ខ្មែរលន់-នល់, ខ្មែរសីហនុ ជាពិសេសសម្លាប់អតីតអ្នករដ្ឋការគ្រប់ផ្នែក គ្រប់ជាន់ថ្នាក់ អ្នកចេះដឹង និស្សិត បញ្ញវ័ន្ត និងព្រះសង្ឃជាដើម ។

★ ឃាតករក្រុមទី២ ៖ មានភារកិច្ចត្រូវសម្លាប់ឃាតករក្រុមទី១វិញ គឺសម្លាប់បក្សខ្មែរក្រហមនិន្នាការខ្មែរ មានខ្មែរក្រហមក្រុមខៀវ-សំផន និងក្រុមខ្មែរក្រហមកើតមកពីចោរព្រៃ ។ ដូច្នេះក្នុងរយៈពេល៤៤ខែ អង្គការចាត់ការសម្លាប់បំផុតពូជខ្មែរ ជាដំណាក់ៗមានលំនាំយ៉ាងស្អាត ។

លុះដល់ឆ្នាំ១៩៧៨ ប្រទេសខ្មែរចំហឆ្លង ។ ឱកាសល្អមកដល់យ៉ាងនេះ យួនហាណូយជាវៀតណាមឈានជំហានទី២ វាក៏បញ្ជាឲ្យបូជួយចេញពីព្រៃ ចូលមកវាតត្បាតលុកលុយពាសពេញទីក្រុងនៃប្រទេសកម្ពុជា ដោយយកលេសថា ចូលមកកំទេចខ្មែរក្រហម ដើម្បីរំដោះខ្មែរ ញ៉ាំងឲ្យរាស្ត្រខ្មែរដែលមិនបានសិក្សានយោបាយ មិនបានតាមដានកលល្បិចខ្មាំង មិនចេះត្រិះរិះពិចារណា ក៏ជឿយួន យល់ច្រឡំយ៉ាងធ្ងន់សែនធ្ងន់ក៏សន្និដ្ឋានថា យួនស្ម័គ្រចិត្តមកស្លាប់ និងមកជួយខ្មែរជាលើកទី៣ ។ ខ្មែរទាំងនេះក៏ដឹកលដ់ដំកើងយួនហាណូយជាវៀតកុង ដែលជាមេឃាតករដែលជាចោរ ទុកជាអ្នកមានឧបការគុណទៅវិញ ។

- ឱ ! បងប្អូនខ្មែរអើយ ! ហេតុអ្វីក៏ស្លូតស្លាប់ម្ល៉េះ ?
- ឱ ! មេដឹកនាំខ្មែរអើយ ! ត្រូវចេះភ្ញាក់រលឹកឡើង !
- បើបណ្ដោយឲ្យរាស្ត្រខ្មែរយល់ច្រឡំយ៉ាងនេះ តើធ្វើម្ដេចរាស្ត្រខ្មែរចេះប្រុង

ប្រយ័ត្ន ?

– តើធ្វើម្តេចរាស្ត្រខ្មែរមានកម្លាំងកាយ កម្លាំងចិត្ត លើកដៃកំទេចខ្មាំង កំទេចចោរ ដើម្បីរំដោះមាតុភូមិកម្ពុជា ?

លោកតាអាងនិយាយដល់ត្រឹមហ្នឹង រ៉ាដាក៏សុំសួរយោបល់លោកតាអាងថា ហេតុម្តេចបានជាអង្គការដេញប្រជាជន ក្នុងមួយនគរជាច្រើនលាននាក់ ឲ្យចេញចោលទីលំនៅឆ្ងាយពីផ្លូវជាតិ ពីដងស្ទឹង មានចម្ងាយយ៉ាងតិច២គ.ម. ? ។

ឮសំនួរដ៏មានខ្លឹមសារនេះ លោកតាអាងមានការឈឺចាប់យ៉ាងក្រៃលែង ។ លោកតាធ្វើមុខស្ងួត ទើបវែកញែកពន្យល់ដូចតទៅ ៖

រឿងនេះអស្ចារ្យណាស់, កាលណោះអាណិកជនយួនវាបែរជាបញ្ជូនមនុស្សអាថ៌កំបាំងទៅប្រាប់ថា ចូរនៅឲ្យស្ងៀម តាមទីកន្លែងរៀងៗខ្លួនសិន ។ វាជន្លៀសតែប្រជាពលរដ្ឋខ្មែរទេ ។ ដូច្នេះរឿងមិនសមទំនងបែបនេះ គឺអង្គការអនាមិកមានព្រៀងគំរោងការណ៍ជាស្រេច ។

ទី១– សម្លាប់ប្រជាពលរដ្ឋខ្មែរដោយមិនបាច់ប្រើអាវុធ ។

ទី២– បញ្ជូលវៀតកុងមកកាន់ប្រទេសខ្មែរប្រមូលអាណិកជនយួនរំដោះ នាំយកទៅលាក់ទុកឯប្រទេសយួន ។

ទី៣– ប្លន់ទ្រព្យសម្បត្តិរបស់ខ្មែរ ដឹកនាំយកទៅកាន់ស្រុកយួន ។

មើលចុះ ! ប្រជាពលរដ្ឋខ្មែរក្នុងមួយនគរដែលមិនទាន់ដល់វេនស្លាប់ ត្រូវតែចេញចោលទីលំនៅ ត្រូវចោលទ្រព្យសម្បត្តិយ៉ាងច្រើនឥតគណនា ។ កំពុងដឹកដៃកូនចៅ សែងមនុស្សចាស់ជរា សែងអ្នកជម្ងឺធ្ងន់ សែងប្រពន្ធទើបកើតកូនរួច ដើរដោយជើងនាំគ្រួសារទៅដេកពាសព្រៃ ពឹងដីជាគ្រែ ពឹងមេឃជាដំបូល កំពុងបន្តកន្ទុយគ្នាស្លាប់ បណ្តាលមកពីឈឺគ្មានថ្នាំ បណ្តាលមកពីដាច់ពោះ បណ្តាលមកពីអស់សង្ឃឹមក៏សម្លាប់ខ្លួន ។

ឆ្លៀតពេលចលាចលនេះ អង្គការបែរជាបញ្ជូនវៀតកុងដែលចេះភាសាខ្មែរ ជាក្រុមៗចូលមកកាន់ស្រុកខ្មែរ ។ ក្រុមខ្លះដើរប្រមូលអាណិកជនយួន ដែលមានទីលំនៅនៅស្រុកខ្មែរ ឲ្យតម្រៀបជួរឡើងឡាននិងចុះទូក មានទំនុកបំរុងបាយទឹកយ៉ាងគ្រប់គ្រាន់ រួចដឹកនាំយកទៅលាក់ទុកឯស្រុកយួន មានចំនួនជាង២សែននាក់ ទុកសំរាប់វាកែឆ្នៃបន្លំធ្វើជាខ្មែរទៅអនាគត ។

ចំណែកឯក្រុមផ្សេងទៀតដើរប្រមូលឡានធំៗ ទូកធំៗ សណ្តោងជាមួយកាណូត រួចប្រមូលទ្រព្យសម្បត្តិនគរខ្មែរទាំងអស់ រៀបឡើងឡាន រៀបចុះទូក ដឹកនាំចេញជាហូរហែរទៅកាន់ប្រទេសយួន ។

ក្បួនឡានទាំងឡាយនោះដឹកតែពេលយប់ ចំណែកក្បួនទូកធំៗ សណ្តោងជា

មួយកាណូតបើកបរ ទាំងថ្ងៃទាំងយប់ ។

ក្នុងរយៈពេល៣ឆ្នាំ ទ្រព្យសម្បត្តិប្រទេសខ្មែរត្រូវយួនហាណូយជារៀតកុងប្រមូលដឹកប្លន់ដឹកនាំចេញអស់រលីង ។ ចូលឆ្នាំ១៩៧៨ អង្គការបញ្ជាឲ្យរុះរើរឺទ្បាធ្វើពីគ្រឿងឈើ ។ លោកតានិយាយដល់ត្រឹមនេះ ក៏លើកដៃចង្អុលកំទេចឥដ្ឋផ្ទះរឺទ្បារបស់យាយទៀង ព្រមទាំងធ្វើអត្ថាធិប្បាយបង្ហាញជាឧទាហរណ៍ ថាដូចជាផ្ទះរឺទ្បារបស់បងទៀងជាដើម និងផ្ទះរឺទ្បាគ្រឿងឈើសង់ស្ថិតនៅភូមិក្រោយវត្តរំដួលជាច្រើនរយគ្រឿង ត្រូវរុះរើ រួចប្រមូលបញ្ចុះទូកដែលឈប់ចតជាហូរហែរនៅដងស្ទឹងសង្កែរមុខវត្តរំដួល ចាប់តាំងពីខែកុម្ភៈឆ្នាំ១៩៧៨និងបន្តៗមក ។ ក្រុមរុះរើផ្ទះទាំងនោះ និងអ្នកទទួលខុសត្រូវក្បួនទូក គឺយួនទាំងអស់ ។

ចុងឆ្នាំ១៩៧៧ និងក្នុងឆ្នាំ១៩៧៨ អង្គការបញ្ជាឲ្យប្រជាជនខ្មែរ ដើរប្រមូលតុជើងម៉ា និងទូរក្នុងសាលារៀននានា បញ្ចុះក្នុងទូកធំៗសណ្តោងជាមួយកាណូតដែលឈប់ចតជាហូរហែរមុខមន្ទីរពេទ្យធំបាត់ដំបង ដឹកនាំចេញជាចុងបង្ហើយ អ្នកទទួលខុសត្រូវក្បួនទាំងនោះ ក៏សុទ្ធតែយួនទាំងអស់ដែរ ។

លោកតាអាងបញ្ជាក់ថា មានរឿងមួយគួរឲ្យចម្លែកណាស់ គឺក្នុងខែមេសាឆ្នាំ១៩៧៨ បង្គការបញ្ជាឲ្យក្រុមឃាតករអាថ៌កំបាំងសម្លាប់អាណិកជនយួន ដែលពួនលាក់ខ្លួននៅក្នុងស្រុកខ្មែរវិញ ។ ឮដូច្នេះយាយគក់សុំសួរកាត់លោកតាអាងថា ៖

- ហេតុម្តេចក៏សម្លាប់យួន បើយើងសន្និដ្ឋានថា អង្គការអនាមិកជាយួននោះ ?

- នេះជាកលល្បិចឆ្លិនភ្នែកប៉ិនប្រសប់យ៉ាងអស្ចារ្យ ។ អង្គការគោរពតាមពាក្យមួយឃ្លា គឺទុកមិនចំណេញដកចេញមិនខាត ពីព្រោះយួនផុននេះជាយួនចោលម្សៀត មិនព្រមទៅតាមរៀតកុង ។ ដូច្នេះអង្គការត្រូវតែសម្លាប់ចោល ដើម្បីបង្វែងនិងលប់ដាន បំភ័ន្តមតិរាស្ត្រខ្មែរ អង្គការសម្លាប់ទាំងខ្មែរ សម្លាប់ទាំងយួន ។ ម៉្យាងទៀតយកលេសដើម្បីយួនហាណូយបញ្ជូនបូដូយចូលមកលុកលុយប្រទេសកម្ពុជា ។ ពេលសម្លាប់អាណិកជនយួននេះ អង្គការលៃបន្លំសម្លាប់ទាំងខ្មែរកម្ពុជាក្រោមទាំងចាស់ទាំងក្មេងទាំងស្រី ចោទថាជាបណ្តាញរបស់យួន ។

ការពិតអង្គការយកចិត្តទុកដាក់តាមដានខ្មែរកម្ពុជាក្រោមជានិច្ច ពីព្រោះអង្គការស្គាល់ជំរៅចិត្តនៃរាស្ត្រខ្មែរកម្ពុជាក្រោម ដែលនាំគ្រួសាររត់ចោលទឹកដីកម្ពុជាក្រោមទុកឲ្យយួន ហើយមកជ្រកសំណាក់នៅកម្ពុជាកណ្តាល ។ គ្រប់ៗរូបនាំមកនូវសេចក្តីឈឺចាប់គំនុំសងសឹកចំពោះយួន ដែលជាសាសន៍ព្រៃផ្សៃ ជាមេឃាតករ ជាចោរប្លន់ទឹកដី ជាចោរសម្លាប់ជាតិសាសន៍ ដូចជាតាំងពីថ្ងៃទី២១ឧសភា១៩៤៩ យួនលេបទឹកដីកម្ពុជាក្រោមជាលើកទី២ ។ យួនហ៊ានបំពានច្បាប់អន្តរជាតិ យួនប្រកាសថា ខ្មែរកម្ពុជាក្រោមចំនួន៤លាននាក់ដែលជាម្ចាស់ទឹកដី ជាជាតិយួនទាំង

អស់ ទោះគ្នាមិនចេះភាសាយួនមួយម៉ាត់ក៏ដោយ ។ អំពើអយុត្តិធម៌នេះញាំងឲ្យរា-ស្ត្រខ្មែរកម្ពុជាក្រោមដែលមានមធ្យោបាយរត់ ក៏នាំគ្រួសាររត់គេចចាកចេញពីក-ណ្តាប់ដៃចោរប្លន់ទឹកដី ចោរប្លន់ជាតិសាសន៍ យកជ្រករស់នៅកម្ពុជាកណ្តាល ដើម្បីរក្សាឲ្យគង់វង់ពូជអំបូរជាជាតិខ្មែរដដែល ។

អង្គការយល់ជំរៅចិត្តរាស្ត្រខ្មែរកម្ពុជាក្រោម ដែលភៀសខ្លួនមកជ្រកនៅកម្ពុ-ជាកណ្តាល បើពេលណាឃើញយួនហាណូយជាវៀតកុង ចូលមកលុកលុយប្រទេសកម្ពុជា មុខជាខ្មែរក្រោមទាំងនោះក្រៅឡើងចង្អុលមុខយួនហាណូយជាវៀតកុង ស្រែកចោទភ្លាម នេះជាអង្គការអនាមិក នេះជាមេឃាតករ ។ មុខជាខ្មែរកម្ពុជាក្រោមយល់ថា វិបត្តិក្នុងប្រទេសខ្មែរ បណ្តាលឲ្យរាស្ត្រខ្មែរត្រូវស្លាប់ជាច្រើនលាននាក់មិនទំនងនេះ គឺយួនហាណូយបន្លំកែឆ្នៃដើម្បីលេបប្រទេសកម្ពុជា បញ្ចូលក្នុងសង់ព័ន្ធឥណ្ឌូចិនទេតើ ! ។ ពីព្រោះរាស្ត្រខ្មែរកម្ពុជាក្រោមស្គាល់ច្បាស់ស្នៀតរបស់យួនហាណូយ វាប៉ិនប្រសប់ប្រើល្បិចកល មានជាបញ្ញោស់មានជាបណ្តោយ គឺដៃមួយអង្អែល ដៃមួយទៀតសំពង សឹងគ្មានសាសន៍ណានៅលើពិភពលោកធ្វើបានដូចវាឡើយ ។ ព្រោះខ្មែរកម្ពុជាក្រោមត្រូវទទួលរងគ្រោះជាច្រើនលើកច្រើនសារដូចជាជំនាន់ « កំពប់តែអុង », ជំនាន់ « លោកឧកញ៉ាសឺន-គុយ », ជំនាន់ « យួនវៀតមិញប្រមូលខ្មែរកម្ពុជាក្រោមដុតក្នុងជង្រុកស្រូវ » ដូច្នេះខ្មែរកម្ពុជាក្រោមមិនជឿដាច់ខាតថា « បូដួយចិត្តល្អស្ម័គ្រចិត្តមកងាប់ជួយខ្មែរឡើយ » ។

អង្គការយល់ថា ខ្មែរកម្ពុជាក្រោមទាំងឡាយនោះ មុខជាមិនឱបដៃនៅស្ងៀមមិនស្រែកអរគុណយួនដូចបងប្អូនខ្មែរខ្លះនៅកម្ពុជាកណ្តាលឡើយ ។ មូលហេតុនេះ ដើម្បីចៀសវាងកុំឲ្យមានឧបសគ្គរាំងដល់យួនហាណូយជាវៀតកុង អង្គការធ្វើជាច្រឡំសម្លាប់រាស្ត្រខ្មែរកម្ពុជាក្រោមទីវរក់ ចោទថាជាយួន ចោទថាជាបណ្តាញរបស់យួន ។

ហេតុការណ៍ដែលលោកតាអាងខំស្រាវជ្រាវ រួចធ្វើអត្ថាធិប្បាយវែកញែកជាហូរហែរមកនេះ អាចបញ្ជាក់បង្ហាញឲ្យខ្មែរយើងយល់ថា អង្គការអនាមិកនិងយួនហាណូយមានផែនការព្រាងទុកជាស្រេចៗ គឺក្នុងរបបរបស់អង្គការ តើយួនត្រូវធ្វើអ្វីបន្តទៅទៀត ? ។ មិនមែនឧប្បត្តិហេតុនៃប្រទេសខ្មែរកើតមានឡើងដោយចៃដន្យឡើយ ។

លោកតាអាងបញ្ជាក់ទៀតថា យួនហាណូយចូលមកលុកលុយប្រទេសខ្មែរជាលើកទី៣ នៅថ្ងៃទី៧មករា១៩៧៩ គឺវាមកជំនួសអង្គការអនាមិកយ៉ាងពិតប្រាកដ ។ មើលចុះ ! បូដួយកំពុងបើកបរឡានដើរប្រមូលយោធាខ្មែរក្រហមក្មេងៗ ដែលអង្គការលត់ដំដល់កំពូលរួចហើយ និងប្រមូលក្រុមខ្មែរក្រហមនិរតី នាំយកមកបំ-

ពាក់អាវុធឲ្យឡើងវិញ ។ ប៉ុន្តែមិនទាន់ឲ្យប្រាក់ខែនៅឡើយទេ គឺឆ្អែប្រឱតក្រុមនេះឲ្យទៅជាចោរសិន ពីព្រោះពេលនោះមាសពេជ្រមានតម្លៃឡើងវិញ ទំនិញនានាក៏លក់ទិញដោយសេរីឡើងវិញ គឺទិញតែនឹងមាស ។ ដូច្នេះជំរុញក្រុមនេះឲ្យក្លាយទៅជាឃាតករមួយលើកទៀត ។ ស្ទៀតនេះគឺជាស្ទៀតវាយទឹកកំចាយត្រី ។ ស្ទៀតនេះប្រសើរណាស់ យួនហាណូយជាវៀតមិញប្រើស្ទៀតនេះកំចាយខ្មែរកម្ពុជា-ក្រោមមួយលើកហើយ ចាប់ពីឆ្នាំ១៩៤៥ដល់ឆ្នាំ១៩៥៤ ។ កាលណោះយួនហាណូយជាវៀតមិញខ្ចីដៃយួនខាងត្បូង ឲ្យសម្លាប់កំចាយ ប្លន់ដុតផ្ទះ ញាំងឲ្យរាស្ត្រខ្មែរកម្ពុជាក្រោមអ្នកចេះដឹង អ្នកមានមធ្យោបាយ ត្រូវតែបង្ខំចិត្តនាំគ្រួសាររត់ចោលទឹកដីជាកេរ្តិ៍មរតកទុកឲ្យយួនៗនៅគរទៅហើយ ។

ឥឡូវស្ទៀតដដែលនេះ គឺយួនហាណូយជាវៀតណាមដដែលកំពុងនាំយកមកសាបព្រួសពាសពេញក្នុងប្រទេសខ្មែរ ។ ប៉ុន្តែវាប្រើកលល្បិចប្រយោល គឺតាមខ្មែរយៈអតីតខ្មែរក្រហមជាខ្មែរអាយ៉ងរបស់វាប្រើស្ទៀតចោរ ។ មូលហេតុនេះប្រជាពលរដ្ឋខ្មែរជាម្ចាស់ទឹកដីកម្ពុជាពិតៗ អស់សង្ឃឹមគ្មានទីពឹង ត្រូវតែបង្ខំចិត្តនាំគ្រួសារដែលសេសសល់នៅរស់បន្តិចបន្តួច ដើរចេញចោលប្រទេសកម្ពុជាជាហូរហែរ បោះបង់ដីជាកេរ្តិ៍មរតកទុកឲ្យយួននៅមួយនគរទៀត ។ ចំណែកយួនហាណូយវាសម្ងំស្ងៀម វាខ្ចីដៃខ្មែរអាយ៉ងជាចោរឲ្យកំទេចខ្មែរសិនចុះ ។ ឆ្លៀតពេលនេះ វាជាចោរយ៉ាងចេញមុខ ។

- មើលចុះ ! វាកំពុងប្រមូលទ្រព្យសម្បត្តិខ្មែរ លើកដាក់ឡានដឹកនាំចេញទៅកាន់ប្រទេសយួនជាហូរហែរដោយសេរី ។ សរុបសេចក្តី យួនហាណូយជាសត្រូវស្ងួរពូជនៃជាតិខ្មែរយើង ជាច្រើនសតវត្សមកហើយ ។ វាប្រើគ្រប់កលល្បិចសម្លាប់បំផុតពូជខ្មែរ ! វាប្រើគ្រប់កលល្បិចដើម្បីកំចាយខ្មែរឲ្យរត់ចោលទឹកដី ! ប៉ុន្តែមាត់របស់វាស្រែកបង្វែងដាន បំភ័ន្តមតិរាស្ត្រខ្មែរ បំភ័ន្តមតិអន្តរជាតិថា បួដួយស្មគ្រចិត្តបូជាឈាមស្រស់សាច់ស្រស់ចូលមកជួយខ្មែរ ។ ការពិតវាចូលមកមួយលើក ៗ វាខំញុះញង់បំបែកបំបាក់ខ្មែរ វាបង្កើតខ្មែរថ្មី គឺខ្មែរអាយ៉ងរបស់វាដូចជា ៖

- សឺន-ង៉ុកមិញ
- ទូ-សាមុត
- ប៉ុល-ពត
- ហេង-សំរិន
- ជា-ស៊ីមជាដើម នាំយកមកជំនួសខ្មែរយើងជាម្ចាស់ទឹកដីកម្ពុជាពិតៗ ។ គ្រប់ៗឧបករណ៍វាសម្ងំលាក់ពុតក្រោយខ្នងខ្មែរអាយ៉ងរបស់វា រង់ចាំឱកាសល្អមកដ-ល់ ទើបវាឈានមួយជំហានៗក្រោកឡើងកំទេចខ្មែរបានយ៉ាងស្អាតវាលាក់មុខបាន

យ៉ាងជិតដដែល ។ ឧទាហរណ៍ដូចជា វាប្រើតែឈ្មោះអង្គការ វាអាចសម្លាប់ប្រជា-ពលរដ្ឋខ្មែរស្លូតត្រង់ ជាពិសេសអ្នកចេះដឹងចំនួន៣លាននាក់ ។

លុះចូលឆ្នាំ១៩៧៩ ប្រទេសកម្ពុជាចំហផ្លូង យួនហាណូយដើររុយចូលមកលុកលុយរាតត្បាតប្រទេសកម្ពុជាយ៉ាងពេញមុខធ្វើព្រងើយ ។

ចំណែកមេដឹកនាំខ្មែរគ្រប់ៗបក្សបះកន្ទុយច្រូង បោលរត់យករួចខ្លួន ប៉ុណ្ណឹងទៅហើយមិនទាន់ភ្ញាក់រលឹកទៀត ។ ចំណែករាស្ត្រខ្មែររត់គេចបីកណ្ដាប់ដៃរបស់អង្គការ បែរជាចូលចំកណ្ដាប់ដៃបូដូយត្រូវបូដូយចង្អុលមុខសំឡុត សួររកប៉ុល-ពត ដែលរាស្ត្រខ្មែរមិនដែលស្គាល់ទាល់តែសោះនោះទៅវិញ ។ មើលចុះ ! សង្គ្រាមក្នុងប្រទេសកម្ពុជាសែនងងឹតអន្ធកា ញ៉ាំងឲ្យប្រទេសកម្ពុជារលាយទៅជាផេះទៅហើយ មិនទាន់ដឹងថាអ្នកណាច្បាំងជាមួយអ្នកណា ? ។ មូលហេតុនេះ ទើបខ្ញុំខំស្រាវជ្រាវទាល់តែរកឃើញអំពីលក្ខណៈនៃសង្គ្រាមក្នុងប្រទេសកម្ពុជា ។ គឺសង្គ្រាមរវាងយួននិងខ្មែរ ! ។

ពេលនោះរ៉ាដាសុំសួរបញ្ជាក់លោកតាអាងថា ៖

- បើអញ្ចឹងអង្គការ គឺយួនហាណូយឬ ?

លោកតាងក់ក្បាលបង្ហាញកាយវិការថា អញ្ចឹងមែន ! ។

រ៉ាដាសុំសួរលោកតាទៀតថា ៖

- ចុះរឿងយួនយកក្បាលខ្មែរធ្វើជាជើងក្រានដាំតែឲ្យអុងនោះ តើជារឿងពិតឬលោកតា ? ។

- សំនួរនេះត្រូវចិត្តគាត់ណាស់ ព្រោះគាត់ចង់ផ្សាយឲ្យកូនចៅខ្មែរជំនាន់ក្រោយដឹងនិងស្គាល់ នូវអំពើឃោរឃៅរបស់យួនចំពោះខ្មែរ ដែលមានសភាពសាហាវជាងសាហាវទៅទៀត ។ លោកតាលើកដៃស្ទាំអង្អែលក្បាលរ៉ាដា ព្រមទាំងឆ្លើយថា

- រឿងនេះជារឿងពិតណាស់ ! ។

គាត់ធ្វើអត្ថាធិប្បាយពីប្រវត្តិ «កំពុបតែអុង» ឲ្យអ្នកទាំងអស់គ្នាស្ដាប់ ។

ពេលនោះស្រីៗមេម៉ាយទាំងអស់ដែលអង្គុយស្ដាប់ ក៏លាន់មាត់ថា ៖

- ឱ ! ពុទ្ធោៗ យួនសម្លាប់ខ្មែរសាហាវមែនៗ ! ។

លោកតាអាងនិទានបន្តទៅទៀតថា លុះចុងសតវត្សទី១៩ គឺក្នុងឆ្នាំ១៨៧១ ក្នុងរបបបារាំងគ្រប់គ្រងឥណ្ឌូចិន ស្រាប់តែមានអុងយួនម្នាក់ចេញប្រកាស៣ខ បង្ខំឲ្យខ្មែរកម្ពុជាក្រោមគោរពតាមវាជាដាច់ខាត ៖

ខទី១- បង្ខំឲ្យខ្មែរកម្ពុជាក្រោមនិយាយភាសាយួន

ខទី២- បង្ខំឲ្យខ្មែរកម្ពុជាក្រោមស្លៀកពាក់របៀបយួន

ខទី៣- បង្ខំឲ្យព្រះសង្ឃខ្មែរកម្ពុជាក្រោមដោះស្បង់ចីពរចោល ត្រូវតែស្លៀក

ខោពាក់អាវដូចលោកយួន ។ ពេលសូត្រធម៌ត្រូវវាយត្រដោកក្បាលត្រីម៉ុកៗ ដូចលោកយួន ។

កាលណោះរាស្ត្រខ្មែរកម្ពុជាក្រោម ក៏ចលាចលក្តៅក្រហាយ នឹងប្រកាសជាច្បាប់ព្រៃផ្សៃរំលោភសិទ្ធិមនុស្សនេះ ។ កំពុងអស់សង្ឃឹម ស្រាប់តែទទួលដំណឹងថា មានវិរៈបុរសខ្មែរម្នាក់ ឈ្មោះឧកញ៉ាសឺន-គុយ ជាចៅហ្វាយខេត្តខេត្តត្រាវិញ-ព្រះត្រពាំង កំពុងចូលទៅតវ៉ាប្រឆាំងជំទាស់ជាមួយអុងយួនដ៏អប្រិយ ដែលចេញប្រកាសនេះ ។

ក្នុងពេលលោកឧកញ៉ាសឺន-គុយចូលទៅតវ៉ានឹងវា អុងយួនអប្រិយសើចរ-លាក់ដូចយក្ស ព្រមតាំងសួរតបយ៉ាងព្រហើនថា ៖

- តើលោកឧកញ៉ាស្ម័គ្រចិត្តយកជីវិតរបស់លោក ទៅប្តូរនឹងលក្ខ័ណទាំងបីនេះឬទេ ? ។

វិរៈបុរសខ្មែរយើងក៏សើច សើចហើយសើចទៀត គឺសើចចំអកតបឲ្យអុងយួននោះវិញ រួចលើកដៃទះទ្រូងឆ្លើយតបយ៉ាងខ្លីថា ៖

- សុខចិត្ត ! ។

អុងយួនភ្ញាក់ ! វាក៏និយាយទូរលេខទៅសុំយោបល់ពីអគ្គទេសាភិបាលឥណ្ឌូចិនប្រចាំការនៅហាណូយ ជាពិសេសវាសុំអនុញ្ញាតកាត់ក្បាលលោកឧកញ៉ាសឺន-គុយ ។

លោកឧកញ៉ាសឺន-គុយ ជាវិរៈបុរសខ្មែរដ៏ក្លាហានធ្វើពលិកម្មប្តូរជីវិតរបស់លោកនឹងលក្ខ័ណទាំងបីខរបស់យួន ដើម្បីរក្សាខ្មែរកម្ពុជាក្រោមឲ្យនៅជាខ្មែរ ទាំងភាសា ទាំងទំនៀមទំលាប់ ទាំងវប្បធម៌ ជាពិសេសព្រះពុទ្ធសាសនា ។

ពេលនោះមហាវិរៈបុរសខ្មែរយើង សុំអនុញ្ញាតពីអុងយួនរៀបចំបាយ នំចំណីនិងផ្លែឈើគ្រប់មុខ មានចំនួន៥ស្លាក ដំកល់ថ្វាយគ្រប់ទិសទាំង៨ រួចលោកចាប់ផ្តើមពិធីបួងសួង ឧទ្ទិសថ្វាយដល់ទេវតា សុំលោកធ្វើជាសាក្សីដល់ខ្លួនរបស់លោកហ៊ានធ្វើពលិកម្ម យកជីវិតរបស់លោកដូរនឹងខទាំងបីរបស់អុងយួននោះ ។ ប៉ុន្តែមុននឹងប្រារព្ធពិធីបួងសួង លោកស្រែកប្រកាសហាមកូនចៅខ្មែរកម្ពុជាក្រោម មិនឲ្យរៀបការជាមួយយួនជាដាច់ខាត ។ លោកទូន្មានកូនចៅខ្មែរជំនាន់ក្រោយ ៖

- ឲ្យខំកសាងវត្ត ។
- ត្រូវគោរពស្តាប់បង្គាប់ព្រះសង្ឃ ដែលជាគ្រូដើម ។

លោកស្គាល់ច្បាស់នូវឫសគល់ខ្មែរ ទំនៀមទំលាប់ អារ្យធម៌ និងវប្បធម៌ខ្មែរ។

- ព្រះសង្ឃត្រូវខំគោរពវិន័យ ។
- ស្រីៗត្រូវចេះគោរពក្រិត្យក្រមប្រពៃណីខ្មែរ ។

លោកឧកញ៉ាំរំលឹកទូន្មានដាស់តឿនកូនចៅខ្មែរកម្ពុជាក្រោមថា ៖

– អាវុធដ៏មុតស័ក្តិសិទ្ធិដែលអាចការពារជាតិបាន គឺខ្មែរត្រូវចេះសាមគ្គីគ្នាពិត ៗ ត្រូវចេះរួបរួមចងបាច់គ្នាឲ្យបានស្អិត ពួតដៃគ្នាជាធ្លុងមួយ ត្រូវចេះអត់ឱនគ្នា ទើបខ្មែរអាចរក្សាជាតិខ្មែរបានគង់វង់ទៅអនាគត ។

– គ្មានសាសន៍ណាស្រឡាញ់ជាតិខ្មែរជាងខ្មែរខ្លួនឯងទេ ! ។

– បើខ្មែរមិនចេះជួយខ្មែរ ក៏មិនដឹងជាសង្ឃឹមលើសាសន៍ណាឲ្យគេមកជួយខ្មែរបានឡើយ ។

– ចូរកុំជឿ កុំទុកចិត្តសាសន៍ដទៃឲ្យសោះ ។

លុះមហាវិរៈបុរសសឹន-គុយទូន្មានផ្តែផ្តាំកូនចៅខ្មែរកម្ពុជាក្រោមរួច លោកក៏ប្រកាសបួងសួងដល់ទេវតាទាំង៨ទិស លោកអំពាវនាវសុំផ្តាំផ្ញើនូវវាសនាអនាគតនៃកូនចៅខ្មែរកម្ពុជាក្រោម ។ លោកសុំទេវតាជួយថែរក្សាការពារកូនចៅខ្មែរកម្ពុជាក្រោមណាដែលស្មោះត្រង់ចំពោះជាតិ ចេះស្នេហាជាតិ ចេះជួយទុក្ខធុរៈខ្មែរ សូមកូនចៅខ្មែរទាំងនោះចាកផុតពីគ្រោះថ្នាក់គ្រប់បែបយ៉ាង សូមប្រកបតែសេចក្តីសុខចំរើន និងអាចឈ្នះសត្រូវទាំង៨ទិស ។ ផ្ទុយទៅវិញ សូមទេវតាផ្តន្ទាទោសយ៉ាងធ្ងន់ដល់ខ្មែរណាដែលក្បត់ខ្មែរ ។

លុះប្រារព្ធពិធីបួងសួងចប់សព្វគ្រប់ហើយ មហាវីរៈបុរសយើងនឹងឃើញឈឺចិត្ត អំពីបញ្ហាកំពប់តែអុង អំពីបញ្ហាយួនលេបទឹកដីកម្ពុជាក្រោមក្នុងឆ្នាំ១៨៤០ នៅក្តៅហុយៗ ។ ឥឡូវខ្លួនរបស់លោកត្រូវចំណាយជីវិតដូរនឹងច្បាប់ព្រៃផ្សៃរបស់យួនអប្រិយបីខនេះទៀត ។ លោកឧកញ៉ាខឹងនឹងយួនណាស់ ក៏ជេរដាក់បណ្តាសារយ៉ាងធ្ងន់ៗដល់អាចោរយួនប្លន់ទឹកដី ជាពិសេសជេរអាអុងយួនអប្រិយដែលជាអ្នកចេញប្រកាសនោះ ។ ឮជេរយ៉ាងដូច្នោះ អុងយួនក៏ដើរទៅមើលលោកឧកញ៉ា ស្រាប់តែស្តកទាំង៨ហោះរឹងៗប្រាវៗមករកក្បាលវា ។ អុងយួនខឹងដាច់ក្បាលដាច់កន្ទុយ ក៏បញ្ជាឲ្យកូនចៅរបស់វាចាប់លោកឧកញ៉ាសឹន-គុយច្រានចូលក្នុងម៉ាស៊ីនកាត់ក ( កាលខ្ញុំនៅតូច ជីតារបស់ខ្ញុំដែលជានាម៉ឺនបំរើផ្ទាល់លោកឧកញ៉ាតែងតែប្រាប់ខ្ញុំថា ម៉ាស៊ីនកាត់កនោះតាំងនៅក្រោមដើមត្នោតក្នុងភូមិបន្ទាយក្រ ។ ប៉ុន្តែលោកតាអាងបានអះអាងថា ម៉ាស៊ីននោះតាំងនៅមុខសាលាឃុំឡុងឌឹកវិញ ) ដែលវាតាំងនៅមុខសាលាឃុំឡុងឌឹក កណ្តាលទីក្រុងព្រះត្រពាំង ។

ក្រោយពេលដែលមហាវីរៈបុរសខ្មែរកម្ពុជាក្រោមចាកស្ថានចោលយើងទៅ ស្រាប់តែមានទូរលេខពីអគ្គទេសាភិបាលឥណ្ឌូចិន ឆ្លើយតបមកពីហាណូយថា ៖

– សេចក្តីតវ៉ារបស់លោកឧកញ៉ាសឹន-គុយ គឺសមរម្យត្រឹមត្រូវតាមលំនាំច្បាប់ ដូច្នេះត្រូវតែយល់ព្រមតាមសុំ ។

ពេលនោះស្រីៗទាំងអស់លាន់មាត់ថា ៖

- តើធ្វើម្ដេចទៅ? បើអុងយួនអប្រិយសម្លាប់លោកឧកញ៉ាផុតទៅហើយនោះ?

លោកតាអាងនិទានបន្ត ៖

- លោកអគ្គទេសាភិបាលឥណ្ឌូចិនមិនព្រងើយកន្តើយទេ លោករកយុត្តិធម៌ឲ្យខ្មែរកម្ពុជាក្រោមដែរ គឺលោកសំរេចឲ្យចាប់អុងយួននោះ ច្រានចូលទៅក្នុងម៉ាស៊ីនដងដែល ដើម្បីបូជាវិញ្ញាណក្ខន្ធវីរៈបុរសខ្មែរយើងវិញ ។

អគ្គទេសាភិបាលឥណ្ឌូចិនអនុញ្ញាតឲ្យរាស្ត្រខ្មែរកម្ពុជាក្រោម ដែលមានលំនៅនៅខេត្តព្រះត្រពាំង ស្ថាបនាចេតិយមួយមានរាងបួនជ្រុងស្មើ ជ្រុងនិមួយៗមានប្រវែង១៥ម៉ែត្រ កំពស់២ម៉ែត្រ ជញ្ជាំងធ្វើអំពីថ្មភ្នំស្ថិតនៅក្នុងវត្តពោធិសាលរាជកំពង់ត្រង់ផ្លូវចូលខាងស្ដាំដៃ កណ្ដាលទីក្រុងព្រះត្រពាំង ដើម្បីដំកល់សាកសពមហាវីរៈបុរសខ្មែរកម្ពុជាក្រោមយើង ។

នៅលើផ្លានោះ ពុទ្ធបរិស័ទខ្មែរកម្ពុជាក្រោមតែងតែមកជួបជុំក្នុងមួយឆ្នាំ២ដងគឺថ្ងៃភ្ជុំបិណ្ឌសែនដូនតា និងពិធីបុណ្យចូលឆ្នាំថ្មី ដើម្បីគោរពពិធីបង្សុកូលឧទ្ទិសចំពោះវិញ្ញាណក្ខន្ធលោកឧកញ៉ាសឺន-គុយ ។

ចាប់តាំងពីពេលនោះមក ខ្មែរកម្ពុជាក្រោមគោរពស្រឡាញ់និងអរគុណបារាំងយ៉ាងជ្រាលជ្រៅ និងស្មោះត្រង់ក្រៃលែង ។

គួររំលឹកឡើងវិញ មើលចុះជិត១០០ឆ្នាំ ខ្មែរកម្ពុជាក្រោមនៅគង់វង់ជាជាតិខ្មែរព្រមទាំងទទួលសេចក្ដីសុខសាន្ត គឺដោយសារបារាំងឧបត្ថម្ភការពារក្នុងរយៈបារាំងគ្រប់គ្រងឥណ្ឌូចិន ក៏ដូចជាប្រាំងទិព្វអាចទប់ទល់នូវអំពើព្រៃផ្សៃរបស់យួនដែលព្យាយាមបំបាត់ពូជខ្មែរកម្ពុជាក្រោម ។ បារាំងបង្កើតសាលារៀនបង្រៀនភាសាខ្មែរអក្សរខ្មែរគ្រប់ៗខេត្ត ដែលខ្មែរកម្ពុជាក្រោមតាំងទីលំនៅ ។ មានបង្កើតអនុវិទ្យាល័យមួយនៅខេត្តកាន់ថើ សំរាប់តែកូនខ្មែរ ។

ដើម្បីរំលឹកនូវឧបការគុណបារាំង សិស្សខ្មែរកម្ពុជាក្រោមតែងតែរៀនមេសូត្រចាំមាត់ដូចតទៅ ៖

« កញ្ជ្រោញចេកអើយ លោតទុំចុងស្វាយ
ស្រុកយើងសប្បាយ ដោយសារបារាំង ។
កាលដើមពិបាក ព្រោះមានចំបាំង
អ្នកស្រុកភ័យខ្លាំង រត់ចូលតែព្រៃ ។
តាំងពីបានលោក ចូលមកអាស្រ័យ
ទុក្ខសោករោគភ័យ វិនាសខ្ចាត់ខ្ចាយ ។

មានផ្លូវមានស្ពាន មានយានទាំងឡាយ
ចេញចូលសព្វសាយ ទាំងសព្វទំនិញ ។
យកមកលក់ដូរ ហូរហែរពាសពេញ
តាមចូលចិត្តទិញ ស៊ីចុកស្លៀកពាក់ ។
ប្រជាប់ប្រជារ គ្មានខ្វះគ្មានអាក់
ទាំងមាសទាំងប្រាក់ សំបូរច្រើនអើយ » ។

មេរៀនសូត្រចាំមាត់នេះ មានន័យទូលំទូលាយ ជាសាក្សីរំលឹកដាស់តឿនពន្យល់បង្ហាញឲ្យកូនចៅខ្មែរទូទៅចេះភ្ញាក់រលឹកឲ្យដឹងថា កាលពីដើមយួនប្រើគ្រប់មធ្យោបាយសម្លាប់បំផុតពូជខ្មែរយ៉ាងសាហាវ ។ កាលណោះខ្មែរយើងរវល់តែរត់ចូលព្រៃ ។ បច្ចុប្បន្ននេះនៅប្រទេសកម្ពុជា ត្រូវរលាយទៅជាផេះ ប្រជាពលរដ្ឋខ្មែររវល់តែរត់ចោលស្រុក រវល់តែរត់ចោលព្រៃ បណ្ដាលមកពីសត្រូវ ។ ឯណេះយួនឯណោះចិន ។ ឥឡូវឆ្នាំ១៩៩២ សៀមប្ដូថៃចាប់ផ្ដើមជាសត្រូវនឹងខ្មែរយើងទៀត ។

ពីព្រោះខ្មែរយើងសុភាពសប្បុរស ចូលចិត្តរស់នៅដោយស្ងប់ស្ងៀម យើងមិនចេះលោភលន់ យើងមិនចេះបង្ករឿងហេតុនឹងប្រទេសជិតខាងឡើយ សូម្បីតែយើងជាពិសេសខ្មែរកម្ពុជាក្រោម រួមរស់ជាមួយបារាំងជិត១០០ឆ្នាំ យើងមិនដែលវិវាទជាមួយបារាំងឡើយ អាចរក្សាទុកជាមិត្តល្អទៅវិញទៅមកក្នុងប្រវត្តិសាស្ត្រ។

ផ្ទុយទៅវិញយួនឈ្លានពាន គឺយួនវាមិននៅស្ងៀមទេ វារៀបចំផែនការ មានទំរង់ជារដ្ឋាភិបាល ទុកបំរុងជាស្រេចៗ ចាប់តាំងពីឆ្នាំ១៩៤៥ វាដាក់គំរោងការយ៉ាងមាំ បើពេលណាបារាំងត្រូវចាញ់ដកថយចេញពីឥណ្ឌូចិន យួនត្រូវតែលេបទឹកដីកម្ពុជាក្រោមជាលើកទី២ភ្លាម ហើយស្របច្បាប់អន្តរជាតិទៀតផង ។

កាលនោះយួនវៀតមិញកំពុងវាយដេញបារាំង ឆ្លៀតពេលចលាចលនោះ វាឆ្លៀតសម្លាប់កំទេចរាស្ត្រខ្មែរកម្ពុជាក្រោម ជាពិសេសអ្នកចេះដឹង គឺវាប្រើស្នៀតវាយទឹកកំចាយត្រី ។ ត្រូវមែន ! បារាំងត្រូវចាញ់ ត្រូវដកថយចេញពីឥណ្ឌូចិននៅខែសីហាឆ្នាំ១៩៥៤ យួនលេបទឹកដីកម្ពុជាក្រោមបាត់ស្រមោល...

យួនចេញបញ្ជាឲ្យបិទទ្វារសាលារៀនជាភាសាខ្មែរភ្លាម ។ វាលៃលកបំបាត់ពូជខ្មែរកម្ពុជាក្រោមជាដំណាក់ៗ ។ មុនដំបូងវាបង្ខំខ្មែរកម្ពុជាក្រោមកាន់កាតដាក់សញ្ជាតិជាយួនដើមកំណើតខ្មែរ ។ ក្នុងរបបង្វៀង-វាន់ធីវ រដ្ឋធម្មនុញ្ញនៃសាធារណរដ្ឋវៀតណាម ត្រង់មាត្រាទី២, ២២, ២៤ និង៣០ ចុះថ្ងៃទី១-៤-៦៧ សំរេចទុកខ្មែរកម្ពុជាក្រោម ជាជនជាតិភាគតិចក្នុងសហគមវៀតណាម ។ លុះដល់ថ្ងៃទី៤-១០-៦៩ រដ្ឋសភានៃសាធារណរដ្ឋវៀតណាមសំរេចជាថ្មីបំបាត់ជាតិខ្មែរ ។

## ចាសន្និដ្ឋានថាខ្មែរកម្ពុជាក្រោមទាំងអស់ជាជាតិយួន !

នឹកគួរឲ្យស្តាយទឹកដីកម្ពុជាក្រោមជាក្រៃលែង ។ នឹកគួរឲ្យស្តាយប្រជាពលរដ្ឋខ្មែរកម្ពុជាក្រោមជាក្រៃលែង ។ ពីឆ្នាំ១៩៦៩ តាមសេចក្តីប្រកាសផ្ទាល់មាត់របស់ង្វៀង-វាន់ធីវបានឲ្យដឹងថា រាស្ត្រខ្មែរកម្ពុជាក្រោមមានចំនួន៩,០៩៧,៥០០នាក់ ។

សៀវភៅមួយមានចំណងជើងថា « Le Viet Nam » សរសេរដោយលោក Pierre Richard Feray បញ្ជាក់ឲ្យដឹងថាក្នុងឆ្នាំ១៩៨៥ រាស្ត្រខ្មែរកម្ពុជាក្រោមមានចំនួន៦,៧២០,០០០នាក់ រស់នៅជុំវិញវត្តមានចំនួន៥៥៦ ។ ព្រះសង្ឃមានចំនួន២៥,០០០អង្គ ។

នឹកទៅគួរឲ្យអាណោចអធម៌បងប្អូនខ្មែរកម្ពុជាក្រោមណាស់ យួនបង្ខំឲ្យកាន់កាតជាជាតិយួន ប៉ុន្តែមានមួយភាគច្រើនមិនចេះអក្សរយួន មិនចេះភាសាយួនទាល់តែសោះ ។

ពេលបារាំងដកថយចេញចោលខ្មែរកម្ពុជាក្រោមពីឆ្នាំ១៩៥៤ បងប្អូនខ្មែរកម្ពុជាក្រោមយើងមួយភាគច្រើន យំសោកស្តាយបារាំងជាក្រៃលែង ពីព្រោះដឹងជាមុនថា មុខជាត្រូវវេទនាគ្រោះ ត្រូវយួនសម្លាប់បំផុតពូជ ត្រូវយួនធ្វើទារុណកម្ម ដូចពីសតវត្សទី១៩សារឡើងវិញជាមិនខាន ។

មែន ! យួនចាត់ការសម្លាប់ធ្វើទារុណកម្មខ្មែរសាហាវជាងពីសតវត្សទី១៩ សាហាវជាងពីជំនាន់ « ប្រយ័ត្នកំពប់តែអុង » ទៅទៀត ។

ឧទាហរណ៍វាប្រើតែឈ្មោះអង្គការអនាមិក វាឆ្វេប្រទេសកម្ពុជាមួយទាំងមូលឲ្យក្លាយទៅជាគំនរឆ្អឹងជាគំនរផេះ យើងបានឃើញផ្ទាល់នឹងភ្នែក ។

ចំណែកបងប្អូនខ្មែរកម្ពុជាក្រោម ត្រូវបាត់សញ្ជាតិ ទោះយួនមានប្រៀបយ៉ាងណាក៏ដោយ បងប្អូនខ្មែរកម្ពុជាក្រោមនៅតែគោរពតាមបណ្តាំរបស់វិរៈបុរសសឹនគុយជានិច្ច ។ គេសាមគ្គីយ៉ាងរម្ចត គេកាន់បានខ្ជាប់ខ្ជួននូវទំនៀមទំលាប់ខ្មែរ និងព្រះពុទ្ធសាសនា ។ គ្រប់ៗពិធីបុណ្យប្រពៃណី គេនាំគ្រួសារទៅជួបជុំគ្នាក្នុងវត្តទាំងប្រុសទាំងស្រី ទាំងចាស់ទាំងក្មេង រួមគ្នាសូត្រធម៌រួចស្តាប់ធម៌ទេសនា ។ រាល់ៗថ្ងៃសិល ចាស់ៗទាំងតាទាំងយាយ ទៅជួបជុំគ្នាក្នុងវត្ត សូត្រធម៌សុំសិល រួចសំរានក្នុងវត្តមួយយប់ ។ យុវជនខ្មែរកម្ពុជាក្រោមភាគច្រើន មុននឹងរៀបអាពាហ៍ពិពាហ៍តែងតែបួសជាព្រះសង្ឃយ៉ាងតិចមួយវស្សាសិន ដើម្បីរៀនអក្សរ ប្រពៃណីទំនៀមទំលាប់ខ្មែរពីព្រះសង្ឃចាស់ទុំ ។ ឧទាហរណ៍បងទ្រី និងប្អូនគីម-ច័ន្ទ មុននឹងបន្តវិជ្ជា ក៏បានបួសជាសង្ឃម្នាក់ៗបាន២វស្សាដែរ ។ រាស្ត្រខ្មែរកម្ពុជាក្រោមនិយាយតែភាសាខ្មែរ ភាគច្រើនរៀបការប្តីប្រពន្ធតែជាមួយខ្មែរតាមប្រពៃណីទំនៀមទំលាប់ខ្មែរជានិច្ច ។

លោកតាអាងនិទានដល់វគ្គនេះ ស្រីៗទាំង១៤នាក់ក៏លាន់មាត់គ្រប់គ្នាប្រសើរ